# លោក ស៊ីវ ហេងឆ័រ បន្តផ្តល់សក្ខីកម្មនៅចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយ សាយមិន ក្រូស័រ

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣

ប្រែសម្រួលដោយ គីមស្រួយ សុខវិសាល

នៅថ្ងៃច័ន្ទ ទី១៥ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្តស្តាប់សក្ខីកម្មរបស់លោក ស៊ីវ ហេងឆ័រ ជាមួយនឹងការបញ្ចប់ការសួរដេញដោលរបស់សហព្រះរាជអជ្ញា និងការចាប់សួរដេញដោលលើសាក្សីរូបនេះពីសំណាក់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ នៅចុងបញ្ចប់នៃសវនាការថ្ងៃនេះ អង្គជំនុំជម្រះពិភាក្សាអំពីការស្នើរសុំរបស់មេធាវីការពារក្តី នួន ជា ទាក់ទងនឹងសារអេឡិចត្រូនិចរបស់ផលិតករខ្សែរភាពយន្ត សត្រូវប្រជាជន ដែលបានជម្រុញឲ្យការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះត្រូវបានផ្អាកកាលពីសប្តាសន៍មុន ។

## សហព្រះរាជអជ្ញាបន្តសួរដេញដោល លោក ស៊ីវ ហេងឆ័រ

សហព្រះរាជ្ញាអន្តរជាតិ ខេត រេយន័រ ចាប់ផ្តើមដោយធ្វើការវិភាគទៅលើបទសម្ភាសន៍មួយ ដែលលោកហេងឆ័របានធ្វើឡើងជាមួយនឹង អៀង សារី កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ ។ សាក្សីអះអាងថា គាត់បានកត់ត្រាការលើកឡើងរបស់ អៀង សារី នៅខណៈពេលដែលគាត់កំពុងធ្វើបទសម្ភាសន៍នោះ ។ អៀង សារីបានបញ្ជាក់ថា «ខៀវ សំផន ក្លាយជាសមាជិកគណៈមជ្ឈិមនៅក្នុងឆ្នាំ១៩៧៦» ប៉ុន្តែមុនការតែងតាំងនេះ ខៀវ សំផន មានធ្វើសកម្មភាពនៅក្នុងជួគណៈមជ្ឈឹមរួចទៅហើយ ។ អៀង សារីបានបន្ថែមទៀតថា ក្នុងឋានៈជាប្រធានមន្ទីរ៨៧០ ខៀវ សំផន បានដឹងនិងពិនិត្យរាល់ការដកហូតនិងការផ្លាស់ប្តូរកម្មាភិបាលទាំងឡាយ ហើយ ខៀវ សំផន បានដឹងថា«ព័ត៌មាននេះឬព័ត៌មាននោះ»ត្រូវបញ្ជូនទៅ«ចំការ» ។ សាក្សីលើកឡើងថាពាក្យចំការ សំដៅទៅថាលស្រែដែលមិនទាន់បានធ្វើការដាំដុះ ។

សាក្សី បកស្រាយថាពាក្យ«ដកចេញ»មានន័យទៅតាមបរិបទដែលយើងប្រើ ហើយពាក្យនេះមិនមានបញ្ជាក់ន័យច្បាស់លាស់នោះទេ ។ ដកចេញ អាចមានន័យច្រើនដូចជា ដកចេញពីតំណែងឬក៏ចាប់ខ្លួន ។

សាក្សីលើកឡើងថា សំដីរបស់ អៀង សារី បានបញ្ជាក់«យ៉ាងច្បាស់» ពីតួនាទីរបស់ ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ ។

សហព្រះរាជអជ្ញា erynr លើកយកឯកសារ E190/1/72 បទសម្ភាសន៍ជាមួយ វ៉ាន់ រិត មកសួរដេញដោលសាក្សី ។ សាក្សី ឆ្លើយតបថាគាត់«បានទៅដល់ផ្ទះ» វ៉ាន់ រិត ផ្ទាល់និងបានធ្វើបទសម្ភាសន៍នៅទីនោះផងដែរ ។ លោក រិត បញ្ជាក់ថា ខៀវ សំផន ក្លាយជាប្រធានគណៈមន្ទីរ៨៧០ បន្ទាប់ពីសមមិត្ត ឌឿន ។

សាក្សីគិតថា ការអះអាងនេះ«ត្រឹមត្រូវ»ពីព្រោះមានបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ពីទំនាក់ទំនងគ្នារវាង ខៀវ សំផន និង រិត ទាក់ទងនឹងបញ្ហាខស្សាហកម្ម ។

សហព្រះរាជអជ្ញា វ៉ើយ៍ន័រ លើកយកកថាខណ្ឌមួយចំនួនដែលដកស្រង់ពីសៀវភៅរបស់សាក្សី មានចំណងជើងថា បេក្ខជនប្រាំពីរដែលត្រូវនាំមកកាត់ទោស ។ នៅក្នុងកថាខណ្ឌដកស្រង់នេះ សាក្សីបានសរសេរបញ្ជាក់ថាក្នុងនាមជាប្រធានគណៈមន្ទីរ៨៧០ ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំសម្ងាត់មួយនៅក្នុងឆ្នាំ១៩៧០ ដែលពេលនោះ ប៉ុល ពត និង មេដឹកនាំផ្សេងទៀតបានចេញសេចក្ដីសម្រេចឲ្យសម្លាប់មេដឹកនាំសំខាន់ៗ ។ ដើម្បីគាំទ្រការលើកឡើងខាងលើនេះ សាក្សីបានលើកយកឯកសារ E3/1915 បទសម្ភាសន៍របស់លោក ណេត ថេយ៉រ ដែលបានធ្វើការនៅក្នុងទីក្រុងបាំងកក និងភ្នំពេញ ហើយបានធ្វើបទសម្ភាសន៍ជាមួយនឹង ឌុច នៅដើមឆ្នាំ១៩៩៩ ជូនអង្គជំនុំជម្រះ ។

នៅទំព័រទី៦៥ នៃសៀវភៅ បេក្ខជនប្រាំពីរដែលត្រូវនាំមកកាត់ទោស (ឯកសារ E3/48) សាក្សីបានបញ្ជាក់ពីរបៀបដែលខ្មែរក្រហមធ្វើរបាយការណ៍បញ្ជូនទៅថ្នាក់ដឹកនាំបក្ស ។ របាយការណ៍មួយចំនួនត្រូវបញ្ជូនជាពិសេសទៅកាន់ ប៉ុល ពត ប៉ុន្តែជាធម្មតាខ្មែរក្រហមប្រើឃ្លាថា «ជូនបង»ឬ«ជូនបក្ស» ។ សៀវភៅនេះក៏បញ្ជាក់ផងដែរថា ជាធម្មតា របាយការណ៍ត្រូវបញ្ជូនទៅកម្មាភិបាលថ្នាក់លើមួយចំនួនទៀត ដូចជា នួន ជា និង មានចំណារនៅក្នុងរបាយការណ៍ទាំងនោះថា ចម្លងជូនគណៈអចិន្ត្រៃយ៍ ។ សាក្សីលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថា គាត់បានពិនិត្យមើលឯកសារប្រហែលជា ចន្លោះពី១២ ទៅ ២៨ឯកសារ ដែលទាក់ទងនឹងរបៀបដែលខ្មែរក្រហមធ្វើរបាយការណ៍ទៅថ្នាក់លើ ។

សហព្រះរាជអជ្ញាលើកយកឯកសារ E3/724 ទស្សនាវដ្ដីទង់បដិវត្តន៍ប្រចាំខែកក្កដាឆ្នាំ១៩៧៥ និង ឯកសារ E3/731 ទស្សនាវដ្ដីទង់បដិវត្តន៍លេខពិសេសពីខែធ្នូ ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៦ ។ សាក្សី បានប្រគល់ឯកសារថតចម្លងនៃទស្សនាវដ្ដីទង់បដិវត្តន៍ទាំងពីរច្បាប់នេះជូនដល់អង្គជំនុំជម្រះរួចមកហើយ ។ សាក្សី ជម្រាបជូនតុលាការថាគាត់រកឃើញនិងពិនិត្យឯកសារនេះលើកដំបូងប្រហែលជានៅឆ្នាំ១៩៨០ ឬ អាចនៅឆ្នាំ១៩៧៩ ។ សាក្សី បានឃើញបណ្ដុំទស្សនាវដ្ដីទង់បដិវត្តន៍ជាលើកដំបូងនៅក្នុងឆ្នាំ ១៩៨០ ។ សាក្សីប្រាកដថាទស្សនាវដ្ដីទង់បដិវត្តន៍ដែលតុលាការយកមកប្រើប្រាស់គឺយកចេញពីបណ្ដុំទស្សនាវដ្ដីបានគាត់បានពិនិត្យឃើញនៅឆ្នាំ១៩៨០ ហើយបណ្ណាសាររបស់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងក៏មានទស្សនាវដ្ដីទង់បដិវត្តន៍នេះដែរ ។

លោក វ៉ិចទ័រ កុបប៉េ មេធាវីការពារក្ដីឲ្យ នួន ជា លើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថាតុលាការបង្ហាញឯកសារចម្លងដែលមានពណ៌ដូចទស្សនាវដ្ដីទង់បដិវត្តន៍ដើមដល់សាក្សី ។ ដោយសារតែភាគីក្នុងសំណុំរឿងនេះធ្លាប់មាការខ្វែងគំនិតគ្នាទាក់ទងនឹងការប្រើប្រាស់ទស្សនាវដ្ដីទាំងនេះ មេធាវីការពារក្ដីចង់ឲ្យកូនក្ដីរបស់ខ្លួន ទទួលបានឯកសារថតចម្លងដូចគ្នានេះផងដែរ ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្ដី សហព្រះរាជអជ្ញា វ៉េយ័ន័រ យល់ព្រមបង្ហាញឯកសារថតចម្លងនេះទៅ នួន ជា ហើយស្នើរសុំឲ្យមន្ត្រីសោតទស្សន៍ដាក់បង្ហាញឯកសារនេះនៅក្នុងអេក្រង់កំព្យូទ័រ ។

តុលាការបង្ហាញទំព័រមួយចំនួននៃទស្សនាវដ្ដីទង់បដិវត្តន និងចំណារដែលមានលើទស្សនាវដ្ដីនោះឲ្យសាក្សីពិនិត្យ ។ សាក្សីអះអាងថា ចំណារនៅលើទំព័រទស្សនាវដ្ដីទាំងនោះជាចំណាររបស់គាត់ ហើយសាក្សីជាអ្នកប្រគល់ទស្សនាវដ្ដីទង់បដិវត្តន៍ទាំងនេះជូនតុលាការ ។

បន្ទាប់មក តុលាការបានអានការការដកស្រង់ ចេញពីទស្សនាវដ្ដីទង់បដិវត្តន៍ប្រចាំខែមករា ឆ្នាំ១៩៧៦ ដែលនិយាយអំពីគោលនយោបាយរបស់ខ្មែររក្រហមក្នុងការ“វាយប្រយុទ្ធផ្នែកនយោបាយជាមួយនឹងសត្រូវ” ។ ការដកស្រង់នេះលើកសរសើរពីជ័យជំនះរបស់បដិវត្តន៍ខ្មែរក្រហមក្នុង “ការប្រយុទ្ធប្រឆាំងដើម្បីក្តោបក្តាប់ប្រជាជន” ដែលខ្មែរក្រហមចាត់ទុកថាជាជោគជ័យមួយ ដែលបដិវត្តន៍នៅជុំវិញពិភពលោកនេះមិនអាចធ្វើបាន ។ ខ្មែរក្រហមចាត់ទុកការប្រយុទ្ធក្តោបក្តាប់ប្រជាជននេះជាផ្នែកមួយដែលនាំឲ្យបដិវត្តន៍របស់ខ្លួនទទួលបានជោគជ័យ ។ ខ្មែរក្រហមបាន“ចម្រាញ់”ប្រជាជនចេញពីខ្មាំង ដោយផ្តោតសំខាន់ទៅលើកត្តាសេដ្ឋកិច្ចនិងគោលជំហរនយោបាយរបស់ប្រជាជន ។ឧទាហរណ៍ជាក់ស្តែង ខ្មែរក្រហម

បានប្រើយុទ្ធសាស្ត្រនេះយ៉ាងមានប្រសិទ្ធភាពនៅ ខុត្តុង និងស្រុកបាណន់ ។

សហព្រះរាជអជ្ញាសួរបញ្ជាក់សាក្សីពីការលើកឡើងផ្សេងទៀតរបស់គាត់ទាក់ទងនឹង «ការក្តោបក្តាប» ប្រជាជនឬមួយជា«ដកហូត» ប្រជាជន ។ បើទោះបីជាគាត់មិនដឹងពីឯកសារ ដែលទាក់ទងនឹងការ «ចម្រាញ់» ប្រជាជននៅស្រុកបាណន់ក៏ដោយ សាក្សី បានធ្វើការបកស្រាយពីការប្រើប្រាស់ពាក្យ «ក្តោបក្តាប់» ដោយលើកឧទាហរណ៍ពីសកម្មភាពដែលក្មេងៗដណ្តើមគ្នាយកស្ករគ្រាប់ ។ សាក្សីណែនាំថាពាក្យក្តោបក្តាប់អាចប្រើនៅក្នុងបរិបទនេះ ដោយសំដៅទៅលើសកម្មភាពដែលក្មេងដណ្តើមគ្នាយកស្ករគ្រាប់ ។

សហព្រះរាជអជ្ញាបន្តពិភាក្សាអំពីយុទ្ធសាស្ត្រយោធារបស់ខ្មែរក្រហម ហើយអានរបាយការណ៍មួយដែលមានចំណងជើងថា «ប្រធានបទ ៖ កិច្ចប្រជុំគំរប់ខួបលើកទី២៣» ។ កិច្ចប្រជុំនេះធ្វើឡើងដើម្បីអបអរសាទរនឹងការតស៊ូរយៈពេល២៣ឆ្នាំប្រឆាំងនឹងសត្រូវ ។ ប៉ុន្តែជាក់ស្តែង សាក្សីបញ្ជាក់ទៅកាន់អង្គជំនុំជម្រះថាកិច្ចប្រជុំគំរប់ខួបលើកទី២៣ដែលខ្មែរក្រហមលើកឡើងខាងលើនេះ ធ្វើឡើងដោយយកទៅតាមការបរិច្ឆេតដែលបង្កើតឡើងដោយខ្មែរក្រហមនៅឆ្នាំ១៩៥១ ។ ខ្មែរក្រហមចាត់ទុកឆ្នាំ១៩៥១ជាថ្ងៃកំណើតរបស់បក្សកុម្មុយនីសកម្ពុជា ។

ឯកសារយុទ្ធសាស្ត្រយោធាខ្មែរក្រហម បានលើកឡើងពីការវាយសម្រុកក្តោបក្តាបប្រជាជននៅជនបទមុន ។ បន្ទាប់មកទៀត ខ្មែរក្រហមប្រើយុទ្ធសាស្ត្រទៅលើប្រជាជនដែលរស់នៅជុំវិញទីក្រុង ។ ឯកសារនេះបានបញ្ជាក់ថាខ្មែរក្រហមប្រើប្រាស់យុទ្ធសាស្ត្រយ៉ាងមានប្រសិទ្ធភាព ។ សាក្សីលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថា បក្សកុម្មុយនីសន៍ចិនក៏ប្រើប្រាស់យុទ្ធសាស្ត្រនេះផងដែរ ប៉ុន្តែសាក្សីមិនចាំថាមានឯកសារខ្មែរក្រហមផ្សេងទៀតដែលនិយាយពីការប្រើប្រាស់យុទ្ធសាស្ត្រនេះ ។

បន្ទាប់មក សហព្រះរាជអជ្ញាអានឯកសារភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិនៅឆ្នាំ១៩៧៥ ជូនអង្គជំនុំជម្រះ ដែលលើកឡើងអំពីសន្ទរកថារបស់ ខៀវ សំផន ។ នៅក្នុងសន្ទរកថានេះ ខៀវ សំផនបានលើកឡើងពីជោគជ័យរបស់ខ្មែរក្រហមដោយនិយាយថា «នេះគឺជាជោគជ័យដ៏ជាប្រវត្តិ សាស្ត្រដ៏ធំបំផុតរបស់ជាតិនិងប្រជាជនយើង ។ ប្រជាជាតិ និងប្រជាជនទាំងអស់នៅលើពិភពលោកស្វាគមន៍យ៉ាងកក់ក្តៅនូវជោគជ័យរបស់ជាតិយើង» ។ សន្ទរកថានេះលើកឡើងផងដែរថាខ្មែរក្រហមវាយកំចាត់ខ្មាំងប្រកបដោយជោគជ័យនៅគ្រប់ផ្នែក ទាំងផ្នែកយោធានិងសេដ្ឋកិច្ច ។ លើសពីនេះទៀត ខ្មែរក្រហម

បានទទួលជោគជ័យក្នុងការ "ជម្រាញ់" ប្រជាជនចេញពីខ្ទាំងដោយផ្អែកទៅលើកត្តាសេដ្ឋកិច្ចនិងកម្មាំងយោធា ។ សន្ទរកថាក៏លើកឡើងដែរថា សត្រូវ "ស្លាប់យ៉ាងឈឺចាប់បំផុត" ។

សាក្សីរាយការណ៍ជូនតុលាការថា គាត់ប្រហែលជាបានអានសន្ទរកថានេះនៅស្ថានទូតសហរដ្ឋអាមេរិកនៅទីក្រុងបាំងកក ក្នុងខែមេសា ឆ្នាំ១៩៧៥ ។

ទាក់ទងនឹងចំនុចពាក់ព័ន្ធមួយទៀត សហព្រះរាជអជ្ញាចោទសួរសាក្សីពីការធ្វើដំណើររបស់គាត់ ចាប់ពីថ្ងៃទី ១១ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ដាច់ឆ្នាំ១៩៧៥ ។ សាក្សីបានរាយការណ៍ជូនអង្គជំនុំជម្រះថា ខ្លួនបានជិះយន្តហោះចេញពីទីក្រុងភ្នំពេញទៅបាំងកក នៅព្រឹកមួយនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ។ ពេលទៅដល់ប្រទេសថៃ សាក្សីបានធ្វើដំណើរទៅព្រំដែនខ្មែរ-ថៃនៅថ្ងៃទី១៧ ខែមេសា ហើយគាត់បានជួបនិងធ្វើបទសម្ភាសន៍ជាមួយនឹងជនភៀសដែលរត់ចេញពីប្រទេសកម្ពុជា ។ បន្ទាប់មកទៀត សាក្សីបានធ្វើដំណើរទៅប្រទេសឡាវ ហើយបានសម្ភាសន៍ជាមួយប្រជាជនដែលភៀសខ្លួនចេញពីប្រទេសកម្ពុជានៅតាមព្រំដែនឡាវ ។ បន្ទាប់ពីបានចំណាយពេលមួយរយៈនៅ តៃវ៉ាន់ សាក្សីបានធ្វើដំណើរទៅ សកលវិទ្យាល ខនែល ទីក្រុងញ៉ូវយក សហរដ្ឋអាមេរិច ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ។

នៅសកលវិទ្យាល័យ ខនែល សាក្សីបន្តធ្វើការស្រាវជ្រាវព័ត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែនៅខណៈនោះ គាត់បានជួបប្រទះនឹងការលំបាកជាច្រើន ។ គាត់ទទួលបានរបាយការណ៍ប្រចាំថ្ងៃពណ៌លឿងដែលរៀបរៀងឡើងដោយទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិ និងអត្ថបទទាក់ទងនឹងរឿងខ្មែរក្រហមដែលគាត់ចេញពីការសែត នៅបណ្ណាល័យសកលវិទ្យាល័យខនែល ។ ក្រៅពីនេះ សាក្សីបានទាក់ទងមិត្តភក្តិជាអ្នកការសែតមួយចំនួននៅទីក្រុងបាំងកក ដែលបន្តសរសេរអត្ថបទពីស្ថានភាពក្នុងប្រទេសកម្ពុជា ។ មន្ត្រីរដ្ឋាភិបាលសហរដ្ឋអាររមេរិក និង អ្នកការសែតម៉ាក់-លេនីន ដែលបានធ្វើដំណើរទៅកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់ព័ត៌មានមួយចំនួនដល់សាក្សីផលដែរ ។ នៅចុងឆ្នាំ ១៩៧៩ សាក្សីបានធ្វើការទាក់ទងដោយផ្ទាល់ជាមួយនឹង អៀង សារី នៅពេលដែលគាត់កំពុងធ្វើទស្សនកិច្ចនៅអង្គការសហប្រជាជាតិ ក្នុងទីក្រុងញ៉ូវយ៉ក ។ តាមរយៈការទាក់ទងដោយផ្ទាល់ជាមួយនឹង អៀង សារី សាក្សីបានរៀបចំដំណើរទស្សនិកច្ចរបបកម្ពុជាប្រជាធិបតេយ្យនៅដើមឆ្នាំ១៩៧៩ ក៏ប៉ុន្តែគម្រោងរបស់គាត់ត្រូវបានខកខានទៅវិញដោយសារតែការឈ្លានពានរបស់វៀតណាម ។

សហព្រះរាជអាជ្ញា វ៉ៃយ៍ន័រ ត្រលប់ទៅបង្ហាញឯកសារមួយទៀត ដែលមានចំណងជើង “ព័ត៌មានពីប្រទេសកម្ពុជា” ដែលបោះពុម្ពផ្សាយនៅ ចុងខែមីនា ឆ្នាំ១៩៧៤ ជូនសាក្សី ។ ឯកសារនេះលើកឡើងពីព្រះរាជសារមួយច្បាប់របស់សម្តេចសីហនុ ដែលទ្រង់បានអបអរសាទរចំពោះដំណើរទស្សនកិច្ចមិត្តភាពរបស់ ខៀវ សំផន នៅប្រទេសវៀតណាម ។ សហព្រះរាជអាជ្ញាបានចោទសួរសាក្សីថាតើគាត់បានដឹងពីដំណើរទស្សនកិច្ចរបស់ ខៀវ សំផន ដែរឬទេ ។ សាក្សីជម្រាបជូនអង្គជំនុំជម្រះថា គាត់បានដឹងពីដំណើរទស្សនកិច្ចនេះ តាមរយៈរបាយការណ៍របស់ទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិ នៅពេលដែលគាត់នៅទីក្រុងភ្នំពេញ ។

ឯកសារនេះបញ្ជាក់ថា “ពួកក្បត់នៅភ្នំពេញ” មិនមានការរៀបចំត្រឹមត្រូវនោះទេ ហើយក្រុមនេះមាននៅគ្រប់ផ្នែកទាំងអស់របស់រណសិរ្ស ។ ការដកស្រង់នេះក៏បានពិភាក្សាអំពីហេតុការណ៍ដែលកើតឡើងនៅកោះដាច់ ដែលស្ថិតនៅតាមដងទន្លេមេគង្គ ។ សាក្សីមិនចាំថាគាត់បានពិនិត្យឯកសារនេះឬអត់នោះទេ ។ បន្ទាប់មកទៀត ខ្មែរក្រហមចាត់ទុកជោគជ័យរបស់ខ្លួននៅឧត្តុងថាបានធ្វើឲ្យទាហានសត្រូវ “បាត់បង់ស្មារតីប្រយុទ្ធ” ។ ពេលដែលសហព្រះរាជអាជ្ញាស្នើរឲ្យសាក្សីធ្វើការបកស្រាយឲ្យបានក្បោះក្បាយពីព្រឹត្តការណ៍នៅឧត្តុង សាក្សីមិនអាចស្មានបានថាតើមានទាហានប៉ុន្មាននាក់បានប្រយុទ្ធគ្នានៅទីនោះទេ ។ សាក្សីជម្រាបទៅកាន់អង្គជំនុំជម្រះថា ជាធម្មតាខ្មែរក្រហមច្រើនតែរាយការណ៍ពន្លើស ហើយជួនកាលច្រើនតែប្រឌិតឡើងពីជោគជ័យរបស់ខ្លួនទៅខ្លាំងសត្រូវ ។

នៅពេលពិភាក្សាអំពីប្រធានបទមន្ទីរសន្តិសុខ សាក្សីលើកឡើងថាមានគុក និងមន្ទីរឃុំឃាំងក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ ប៉ុន្តែក្រោយមកចំនួនគុកនិងមន្ទីរឃុំឃាំងបានថយចុះ ។

សហព្រះរាជអាជ្ញាអានការដកស្រង់មួយទៀតចេញពីសៀវភៅ “ព័ត៌មានពីប្រទេសកម្ពុជា” ដែលលើកឡើងពីសន្ទរកថារបស់ ខៀវ សំផន នៅប្រទេសកូរ៉េខាងជើង ជូនអង្គជំនុំជម្រះ ។ នៅក្នុងសន្ទរកថានោះ ខៀវ សំផន លើកឡើងថាការវាយសម្រុករបស់ទាហានខ្មែរក្រហមបានជាប់គាំងនៅឧត្តុង ។ ទាហានខ្មែរក្រហមរំដោះបានឧត្តុងពីទាហានសត្រូវប្រមាណ៥ ០ ០ ០ នាក់ ។ សាក្សីជម្រាបជូនអង្គជំនុំជម្រះថា គាត់ចាំច្បាស់ណាស់ថាគាត់បានអានការវាយរំដោះឧត្តុងរបស់ខ្មែរក្រហម តាមរយៈរបាយការណ៍ដែលធ្វើឡើងដោយទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិ ។

សហព្រះរាជអាជ្ញា វ៉ើយ៍ន័រ បន្តដេញដោលលើប្រធានបទនេះ ហើយបានដកស្រង់កថាព័ត៌មានពី សៀវភៅរបស់ បេន គៀនន់ មកធ្វើការពិភាក្សា ។ កថាខណ្ឌដកស្រង់នេះ អះអាងថានៅខែមិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិម បានបើកកិច្ចប្រជុំនិងចេញសេចក្តីសម្រេចឲ្យធ្វើការវាយសម្រុករំដោះប្រទេសទាំងមូល ។ សាក្សីជម្រាបជូនអង្គជំនុំជម្រះថាគាត់ដឹងពីឯកសារយោងដែលទាក់ទងនឹងកិច្ចប្រជុំនៅក្នុងឆ្នាំ១៩៧៤ ។

សហព្រះរាជអាជ្ញា អានកថាខណ្ឌដកស្រង់មួយទៀតចេញពីឯកសារបក្សកុម្មុយនិស្តកម្ពុជា ហើយឯកសារនេះបានលើកសរសើរពីវិធីដែលខ្មែរក្រហមកាត់ផ្តាច់ប្រពន្ធ័ទំនាក់ទំនងរបស់ខ្មាំង ។ ឯកសារនេះបានលើកឡើងថា នៅពេលដំបូង«យើង»ចាប់កាត់ផ្តាច់ទីតាំងរបស់ខ្មាំងនៅជនបទ ។ ក្រោយមក សត្រូវត្រូវបានកាត់ផ្តាច់ ខ្មែរក្រហមបានធ្វើការចល័តប្រជាជន ។ ប្រព័ន្ធទំនាក់ទំនង និងស្បៀងរបស់សត្រូវត្រូវបានកាត់ផ្តាច់ ។ ឯកសារនេះលើកឡើងផងដែរថា «នៅពេលដែលប្រព័ន្ធទាក់ទងរបស់ខ្មាំងទាំងនៅលើដីគោក និងតាមដងទន្លេមេគង្គត្រូវបានកាត់ផ្តាច់នៅឆ្នាំ១៩៧៤ ទំនាក់ទំនងរវាងពួកចក្រពត្តិអាមេរិក និងលន់ នល់ ក៏ត្រូវបានកាត់ផ្តាច់ដែរ» ។ ឯកសារនេះបញ្ជាក់ទៀតថា «ដោយសង្កេតឃើញសភាពការណ៍បែបនេះ គណៈមជ្ឈិមបានចេញសេចក្តីសម្រេចឲ្យមានការវាយសម្រុករំដោះយកទីក្រុងភ្នំពេញ និងប្រទេសកម្ពុជាទាំងមូល» ។

សាក្សីជម្រាប់តុលាការថា នៅក្នុងកថាខណ្ឌដកស្រង់នេះ ខ្មែរក្រហមប្រើពាក្យ "មជ្ឈិមបក្ស" ហើយមិនមែនសំដៅទៅ គណៈមជ្ឈិមបក្សនោះទេ ។ សាក្សីបញ្ជាក់ថែមទៀតថា ខៀវ សំផន បានក្លាយជាសមាជិកពេញសិទ្ធនៅគណៈមជ្ឈិម ពេលដែលគាត់ផ្តល់សក្ខីកម្មកាលពីថ្ងៃមុន ។

សហព្រះរាជអាជ្ញា វ៉ើយ៍ន័រ លើកយកអត្ថបទការសែត ញូវយ៉កថែម ដែលចេញផ្សាយនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨២ និងអានកថាខណ្ឌដែលបញ្ជាក់ថា ខៀវ សំផន ទទួលស្គាល់ពីសេចក្តីសម្រេចរួមមួយក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ហើយ ខៀវ សំផន ខ្លួនឯងផ្ទាល់មានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ។ នៅពេលសួរថាតើលោកមានឯកសារ និងបទសម្ភាសន៍ណាដែលលើកឡើងពីការពាក់ព័ន្ធរបស់ ខៀវ សំផននោះទេ សាក្សីមិនបានដឹងថាពីឯកសារពាក់ពន្ធ័នឹងរឿងនេះទេ ។

ឯកសារពីរទៀតដែលចងក្រងដោយ អង្គការលើកលែងទោសអន្តរជាតិ ត្រូវបានលើកមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ។ ឯកសារទីមួយជាសំបុត្រដែល អៃ ផ្ញើរជូន ខៀវ សំផន ទាក់ទងនឹងការ

បញ្ជូនប្រជាជនដែលរត់ទៅប្រទេសថៃ មកកម្ពុជាប្រជាធិបតេយ្យវិញ ។ ឯកសារទីពីរជាសេចក្តីប្រកាសសារព័ត៌មាននៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ដែលលើកឡើងពីការព្រួយបារម្ភរបស់ខ្លួន ដោយសាររបបកម្ពុជាប្រជាធិបតេយ្យមិនបានចាត់វិធានមានប្រសិទ្ធភាពដើម្បីដោះស្រាយសេចក្តីអំពាវនាវរបស់ខ្លួន ។ អង្គការសិទ្ធិមនុស្សអន្តរជាតិបានអំពាវនាវឲ្យ ខៀវ សំផន ធានាពីជោគវាសនារបស់ប្រជាជនខ្មែរ២៦នាក់ ភាគច្រើនជាកសិករ នៅពេលដែលក្រុមនេះត្រូវបញ្ជូនពីប្រទេសថៃទៅកម្ពុជាប្រជាធិយតេយ្យវិញ ។ អង្គការសិទ្ធិមនុស្សអន្តរជាតិលើកឡើងពីការបារម្ភណ៍របស់ខ្លួន ដោយសារតែរបបខ្មែរក្រហមបានធ្វើការកាប់សម្លាប់ប្រជាជនរបស់ខ្លួន ។ សាក្សីមិនបានដឹងពីការឆ្លើយតបរបស់កម្ពុជាប្រជាធិបតេយ្យទៅនឹងការលើកឡើងនេះទេ ។

លើសពីនេះទៀត សាក្សីនិយាយថា ពេលដែលគាត់ជួប អៀង សារី នៅទីក្រុងញ៉ូវយ៉ក អៀង សារី មិនបានឆ្លើយតបនឹងការចោតប្រកាន់អំពីអំពើយង់ឃ្នងរបស់របបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ អៀង សារី បានប្រគល់ឯកសារសាធារណៈមួយច្បាប់ជូនអង្គការសហប្រជាជាតិ ដែលចាត់ទុកការចោទប្រកាន់នោះគ្រាន់ជាការឃោសនាមួយ ។

សហព្រះរាជអជ្ញាចោទសួរសាក្សីអំពីស្ថានភាពសិទ្ធិមនុស្សនៅទីក្រុងភ្នំពេញ នៅពេលដែលគាត់បានរស់នៅទីនោះក្នុងឆ្នាំ១៩៧៤ ។ សាក្សីបានឆ្លើយតបវិញថា ចំនួនប្រជាជនក្នុងក្រុងភ្នំពេញកើនឡើងជាលំដាប់ ហើយខ្មែរក្រហមបាញ់ផ្លោងកាំភ្លើងធំចូលក្នុងក្រុងជាបន្តបន្ទាប់ចាប់ពីខែប្រាំងឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៥ ។ សាក្សីលើកឡើងថា ក្រៅពីការបាញ់ផ្លោងកាំភ្លើងធំចូលក្រុងភ្នំពេញ ការវាយប្រយុទ្ធគ្នាបានថយចុះចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៤ ។ ខណៈនោះមានមនុស្សមួយចំនួនយល់ថាកម្លាំងរបស់ខ្មែរក្រហមកំពុងតែចុះថយ ក៏ប៉ុន្តែ សាក្សីបានលើកឡើងថាបុគ្គលិកយោធានៅស្ថានទូតជប៉ុនម្នាក់ដែលគាត់បានលើកមកនិយាយកាលពីថ្ងៃមុន បានប្រាប់គាត់ថាខ្មែរក្រហមកំពុងតែប្រមូលផ្តុំកម្លាំងទាំងអស់ដើម្បីធ្វើការវាយប្រហារក្នុងទ្រង់ទ្រាយធំ ។

នៅក្នុងអំឡុងពេលនោះប្រធានចលនានិសិត្សនៅទីក្រុងភ្នំពេញឈ្មោះ ពីង បានប្រាប់សាក្សីថាប្រជាជនមិនចាំបាច់ព្រួយបារម្ភពីសភាពការណ៍ប្រទេសជាតិ ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចនោះទេ ពីព្រោះប្រជាជននឹងធ្វើការនៅតាមវាលស្រែ មិនមែនធ្វើការនៅក្នុងទីក្រុងនោះទេ ។ សាក្សីយល់

បានថាលើកឡើងរបស់ប្រធាននិសិត្សរូបនេះជាព័ត៌មានគួរឲ្យចាប់អារម្មណ៍មួយ ក៏ប៉ុន្តែពេលនោះ សាក្សី មិនបានចាប់អារម្មណ៍ពីសារៈសំខាន់នៃព័ត៌មានដែលខ្លួនបានទទួលនោះទេ ។

តាមរយៈកិច្ចពិភាក្សាជាមួយបុគ្គលិកយោធាស្ថានទូតជប៉ុន សាក្សីបានដឹងថាទន្លេមេគង្គជាផ្លូវដឹកជញ្ជូនដ៏សំខាន់សម្រាប់ផ្គត់ផ្គង់សម្ភារៈយោធានិងស្បៀងដល់រដ្ឋការ លន់ នល់នៅក្រុងភ្នំពេញ ។ សាក្សីនិយាយបន្ថែមថា ហេតុដូច្នេះហើយបានជាទាហានខ្មែរក្រហមនៅភូមិភាគបូព៌ា និងភូមិភាគពិសេសដាក់មីននៅក្នុងទន្លេបង្អាក់ចរាចរណ៍នាវានៅតាមដងទន្លេ ។ សាក្សីបញ្ជាក់គាត់មិនឃើញមីនទាំងនោះផ្ទាល់ភ្នែកទេ ។ ប៉ុន្តែ គាត់អះអាងថាគាត់បានដឹងព័ត៌មាននេះពីបុគ្គលិកយោធាស្ថានទូតជប៉ុន ។ លើសពីនេះទៅទៀត សាក្សីនៅចាំថាខ្មែរក្រហមយករូបថតនាវាដែលខ្មែរក្រហមបាញ់ ហើយនាវាទាំងនោះបកក្បាលត្រឡប់ក្រោយវិញដូចនឹងកាំភ្លើងដែលបាញ់ថយក្រោយ ដើម្បីបម្រើដល់ការឃោសនារបស់ខ្លួន ។

សាក្សីនៅចាំបានពី “ជំនួយតាមអាកាស” បន្ទាប់ពីខ្មែរក្រហមដាក់គ្រាប់បែកតាមដងទន្លេ អាមេរិកបានប្តូរយុទ្ធសាស្ត្រមកទម្លាក់ស្បៀងនិងអាវុធតាមយន្តហោះក្នុងទីក្រុងភ្នំពេញ ។ ការទម្លាក់ស្បៀងតាមយន្តហោះនេះបានបញ្ចប់តែប៉ុន្មានថ្ងៃ ឬប៉ុន្មានអាទិត្យប៉ុណ្ណោះមុន ពេលអាមេរិកជម្លៀសបុគ្គលិករបស់ខ្លួនចេញពីប្រទេសកម្ពុជា ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥ ។

សាក្សីបានជួបជនភៀសកម្ពុជាដែលរត់គេចខ្លួនពីការប្រយុទ្ធគ្នា និងការវាយសម្រុករបស់ទាហានខ្មែរក្រហមនៅតាមព្រំដែនខ្មែរ-ថៃ ។ សាក្សីបានដឹងពីការសម្លាប់រង្គាលរបស់ទាហានខ្មែរក្រហមលើប្រជាជន ប៉ុន្តែនៅពេលនោះ គាត់ពិបាកនឹងប្រមូលឯកសារដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីការសម្លាប់រង្គាលនោះ ។

តាមរយៈបទសម្ភាសន៍ជាមួយនឹង អៀង សារី សាក្សីបានសរសេរថាខ្មែរក្រហមមិនមានគម្រោងប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ ក៏ប៉ុន្តែសាក្សីអះអាងថាអំពើប្រល័យពូជសាសន៍កើតឡើងដោយសារតែគោលនយោបាយបួយយ៉ាង ៖ ការបម្រាញ់ប្រជាជនទៅជាវណ្ណៈអធនដោយបង្ខំ ការធ្វើតូនិយកម្មខ្មែរនិយមដោយបង្ខំនិងក្នុងរយៈពេលយ៉ាងខ្លី ការចាត់ទុកជនណាក៏ដោយឲ្យតែប្រឆាំងនឹងបដិវត្តន៍ឬធ្វើការងារមិនបានសម្រេចតាមផែនការជាខ្មាំងឬជាសត្រូវរបស់បក្ស និងការចាប់ខ្លួន ទារុណកម្ម និងការសម្លាប់ជនទាំងឡាយណាដែលត្រូវបានចោទថាជាខ្មាំងឬសត្រូវ ។ បទសម្ភាសន៍នេះក៏បញ្ជាក់ផង

ដែរថា ចាប់តាំងពីថ្នាក់ភូមិភាគរហូតដល់សហករណ៍សុទ្ធតែមានអំណាចក្នុងការចាប់ខ្លួន ធ្វើទារុណកម្ម និង សម្លាប់មនុស្ស ហើយខ្មែរក្រហមបានប្រើប្រាស់ចម្លើយសារភាពដែលមិនពិតទៅចាប់មនុស្សផ្សេងទៀតមកធ្វើទារុណកម្មជាបន្តបន្ទាប់ ។

សហព្រះរាជអាជ្ញាចោទសួរសាក្សីថាតើគាត់មានបានរំពឹងទុកថាខ្លួននឹងត្រូវឆ្លើយនឹងសំនួរនេះឬទេ ឬមួយក៏សហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់គ្រាន់តែសួរសំនួរនេះដោយចៃដន្យទេ ។ មុនពេលដែលសាក្សីឆ្លើយតបនឹងសំនួររបស់សហព្រះរាជអាជ្ញា អង់តា ហ្គីសសេ សហមេធាវីការពារក្តី ខៀវ សំផន ធ្វើការជំទាស់ដោយលើកឡើងថាសំនួររបស់សហព្រះរាជអាជ្ញាសំដៅទៅអំពើប្រល័យពូជសាសន៍ ដែលមិនជាប្រធានបទនៃសវនាការនៅថ្ងៃនេះទេ ។

ជាការឆ្លើយតប សហព្រះរាជអាជ្ញា វ៉េយ៍ន័រ សន្យាថាគាត់នឹងមិនប្រើពាក្យអំពើប្រល័យពូជសាសន៍ម្តងទៀតទេ នៅពេលដែលគាត់សួរដេញដោលសាក្សី ។ ប៉ុន្តែ លោកចៅក្រម ហ្សង់ម៉ាក ឡាវីញប្រកាសនៅមុខអង្គជំនុំជម្រះថាសំនួរនេះទាក់ទងនឹងសំនួរ ដែលសាក្សីបានចោទសួរ អៀង សារី នៅក្នុងបទសម្ភាសន៍របស់គាត់ ហើយហេតុដូច្នេះ សហព្រះរាជអាជ្ញាអាចចោទចោទសួរនិងប្រើពាក្យអំពើប្រល័យពូជសាសន៍នេះបាន ។

នៅទីបំផុត អង្គជំនុំជម្រះសម្រេចថា សាក្សីជឿជាក់ថារូបគាត់បានធ្វើការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់ពីចំនុចដែលលើកឡើងទាំងអស់នេះ ។ សាក្សីប្រើពាក្យ «អំពើប្រល័យពូជសាសន៍» ដើម្បីជម្រុញឲ្យ អៀង សារី ឆ្លើយថា «គាត់ក៏មើលឃើញសភាពបែបនេះដែរ» ។ អៀង សារី និយាយនៅក្នុងបទសម្ភាសន៍នោះថា «ការប្រព្រឹត្តបែបនេះគឺខុសទាំងស្រុង ។ បើសិនជាអំពើបែបនេះកើតឡើងពីកន្លែងមួយទៅកន្លែងមួយទៀតនោះ ជាតិយើងទាំងមូលនឹងទទួលរងការឈឺចាប់ ។ នេះគឺជាគំនិតរបស់ខ្ញុំទាក់ទងនឹងការលើកឡើងរបស់លោក» ។ អៀង សារីបន្តទៀតថា បដិវត្តន៍ខ្មែរក្រហមឆ្លងកាត់ភាពស្មុគស្មាញជាច្រើន ហើយចំនួនសត្រូវកើនឡើងជាលំដាប់ ។

សាក្សីបានចោទសួរ អៀង សារី នៅពេលដែលចេញសេចក្តីសម្រេចឲ្យ «ធ្វើសកម្មភាពបែបនេះ» ខ្មែរក្រហមលើកឡើងថាវាមានការចាំបាច់តម្រូវឲ្យក្រុមរបស់ខ្លួនត្រូវអនុវត្តន៍សេចក្តីសម្រេចនេះឲ្យបានឆាប់ ។ អៀង សារី អះអាងថាសកម្មភាពបែបនេះត្រូវខ្មែរក្រហមយកទៅអនុវត្តន៍ភ្លាមៗ បន្ទាប់ពីជ័យ

ជនះរបស់ខ្លួន និងនៅក្នុងចុងឆ្នាំ១៩៧៥ ។ អៀង សារី អះអាងថា សមាជិកក្នុងគណមជ្ឈឹម ដូចជា នួន ជា ប៉ុល ពត និង ខៀវ សំផន សុទ្ធតែមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ពេលដែលសេចក្តីសម្រេចត្រូវបានអនុម័ត្ត ។

ទាក់ទងនឹងប្រធានបទចុងក្រោយ សហព្រះរាជអជ្ញា វ៉េយ៍ន័រ ចោទសួរសាក្សីពីការការជម្លៀសប្រជាជនទៅប៉ែកពាយ័ព្យប្រទេស ដោយមិនរាប់បញ្ចូលការជម្លៀសប្រជាជនក្នុងខែមេសា ឆ្នាំ១៩៧៥នោះទេ ។ សាក្សីឆ្លើយតបទៅកាន់អង្គជំនុំជម្រះវិញថា គាត់មានបានធ្វើបទសម្ភាសន៍ ដោយផ្តោតទៅលើការស្ទង់មតិពីចំនួនមនុស្សដែលបានស្លាប់ ជាមួយនឹងប្រជាជនដែលត្រូវខ្មែរក្រហមជម្លៀសនៅក្រោយ ខែមេសា ឆ្នាំ១៩៧៥ ។ សាក្សីនិយាយថាប្រជាជនមួយចំនួនបានត្រៀមខ្លួនរួចជាស្រាចដើម្បីចាក់ចេញ ប៉ុន្តែមានប្រជាជនខ្លះមិនចង់បោះបង់ចោលស្រែ ដែលមានស្រូវទុំអាចនឹងច្រូតបានហើយនោះទេ ។ សាក្សីបន្ថែមថាប្រជាជនដែលមិនចង់ចាក់ចេញ ត្រូវខ្មែរក្រហមបង្ខំឲ្យចេញ ហើយប្រជាជនភាគច្រើនចាក់ចេញតាមបញ្ជារបស់ខ្មែរក្រហម ពីព្រោះគេដឹងថាបើអ្នកដែលប្រឆាំងមុខជានឹងត្រូវបានយកទៅឃុំខ្លួនឬមួយយកទៅសម្លាប់ចោលតែម្តង ។

## សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលសាក្សី

អេលីហ្សាប៉ែត ស៊ីម៉ុណូហុត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចាប់ផ្តើមសួរដេញដោលសាក្សី ។ ប្រធានបទទីមួយដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចោទសួរសាក្សីគឺស្ថានភាពនៅចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៥ ជាពេលដែលសាក្សីរស់នៅក្នុងក្រុងភ្នំពេញ ។ សហមេធាវីនាំមុតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរសាក្សីថា តើគាត់បានឃើញហេតុការណ៍អ្វីខ្លះដែលកើតមានឡើងក្នុងតំបន់រំដោះ តាមរយៈជនភៀសខ្លួនដែលរត់មកជ្រកកោននៅទីក្រុងភំពេញ ។ សាក្សីឆ្លើយតបវិញថា គាត់បានដឹងហេតុការណ៍ដែលកើតមានជាទូទៅនៅក្នុងតំបន់រំដោះ រួមទាំងផលិតផលស្រូវ និងការសម្លាប់មនុស្ស ប៉ុន្តែពេលនោះសាក្សីបានផ្តោតសំខាន់ទៅលើរចនាសម្ពន្ធ័និងការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយគាត់មិនធ្វើការសង្កត់ធ្ងន់ទៅអ្វីដែលប្រជាជនបានជួបប្រទះនោះទេ ។ សាក្សីនិយាយបន្ថែមថាជាមួយនឹងព័ត៌មានដែលគាត់ទទួលបានពីអ្នករត់ភៀសខ្លួនមកក្រុងភ្នំពេញ គាត់គួរតែបានស្រាវជ្រាវលើចំនុចផ្សេងទៀត ។ ក្រៅពី ខត្តុងនិងកំពង់ចាម គាត់បានធ្វើដំណើរទៅដល់ខេត្តបាត់ដំបង ក៏ប៉ុន្តែពេលនោះបាត់ដំបងមិនមែនជាតំបន់រំដោះដែលគ្រប់គ្រងដោយខ្មែរក្រហមនោះទេ ។

សហមេធាវីនាំមុខ ស៊ីម៉ុណូហូត អានការដកស្រង់មួយចំនួនពីសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជូនសាក្សី ហើយចោទសួរថាតើសាក្សីមានបានដឹងពីឯកសារដែលដូចគ្នានឹងការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែរឬទេ ។

សក្ខីកម្មទីមួយគឺបទសម្ភាសន៍របស់សាក្សីជាមួយនឹងជនភៀសខ្លួនម្នាក់ ហើយជនភៀសខ្លួនម្នាក់នោះប្រហែលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា ។ ជនភៀសខ្លួននោះលើកឡើងថា «ខ្ញុំគិតថាផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាផ្នែកមួយនៃគោលនយោបាយទូទៅរបស់ខ្មែរក្រហម ដែលត្រូវបានសម្រេចជាយូរមកហើយ» ហើយការបែងចែកប្រជាជនទៅតាមកម្លាំងការងារផ្សេងៗធ្វើឡើងដើម្បីកំចាត់សត្រូវ ។ សាក្សីបញ្ជាក់ថាការលើកឡើងខាងលើនេះគឺពិតជាត្រឹមត្រូវ ។

សាក្សីលើកឡើងថា ពេលដែលគាត់ធ្វើបទសម្ភាសន៍ជាមួយនឹងជនភៀសខ្លួនដែលកំពុងសុំសិទ្ធជ្រកកោននៅតាមព្រំដែនថៃ គាត់បានជួបនឹងប្រជាជនជាច្រើនដែលរត់ចេញពីខេត្តសៀមរាប និងខេត្តបាត់ដំបងហើយពួកគាត់បាននិយាយពីការសម្លាប់នាយទាហានជាន់ខ្ពស់ អ្នករដ្ឋការនល់ នល់ និងការការគំរាមទម្លាក់គ្រាប់បែករបស់កងទ័ពអាកាសរបស់របបសាធារណរដ្ឋ លន់ នល់ ។ សាក្សីលើកឡើងថាប្រជាជនដែលខ្មែរក្រហមជម្លៀសត្រូវចាក់ចេញពីផ្ទះក្រោមបញ្ញាយ៉ាងតឹងរឹង ។

សាក្សីមិនចាំថា មានជនភៀសខ្លួនណាមួយលើកឡើងថាពីការសម្លាប់ប្រជាជនដែលប្រកែកមិនព្រមចាកចេញពីផ្ទះរបស់គាត់ ក៏ប៉ុន្តែគាត់បានដឹងថាខ្មែរក្រហមភ្ជង់កាំភ្លើងដាក់ប្រជាជនហើយបង្ខំប្រជាជនឲ្យចាកចេញពីផ្ទះ ។ នៅពេលសហមេធាវីនាំមុខសួរថាហេតុអ្វីបានប្រជាជនរត់ភៀសខ្លួនចេញពីប្រទេសកម្ពុជាសាក្សីឆ្លើយតបវិញ អ្នកដែលរត់ទៅក្រៅប្រទេសភាគច្រើនជាអ្នកមានធូរធានៅក្នុងរបបមុន និងក្រុមនេះនឹងមានគ្រោះថ្នាក់ បើសិនជារស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីលើកឡើងថាប្រជាជនបាននិយាយពីមាត់មួយទៅមាត់មួយទៀតពីការសម្លាប់របស់ខ្មែរក្រហម ដោយយកលេសថានាំប្រជាជនទៅទទួលសម្ដេចព្រះសីហនុ ឬត្រលប់ទៅកាន់តំណែងដើមរបស់ខ្លួនវិញ ។

សហមេធាវីនាំមុខ ស៊ីម៉ុណូហូត អាចសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ ដូចខាងក្រោម ៖

> នៅពេលដែលអង្គការស្នើរឲ្យរៀបចំរបស់របរ យើងក៏រៀបចំតាមគេប្រាប់ ។ យើងត្រៀមខ្លួនចាកចេញជាមួយអីវ៉ាន់បន្តិចបន្តិច ដូចជាអំបិលជាដើម ។ យើងក៏ចាកចេញពីផ្ទះ ។ នៅថ្ងៃនោះមាន មនុស្ស ក្មេង ចាស់ ប្រុស ស្រី ដើរពេញផ្លូវ ហើយចេញពីគ្រប់ទិសទាំងអស់ ។ ក្មេងៗយំដោយសារបាត់ឪពុកម្តាយរបស់គេ ។ គ្រួសាររបស់ខ្ញុំដើរប្រាំពីរថ្ងៃ ។ នៅពេលដែលយើងទៅដល់ទីនោះ យើងឃើញសាកសពទាហានលន់ នល់ ។

សាក្សីបញ្ជាក់ថាគាត់បានស្តាប់ការសក្ខីកម្មខាងលើនេះពីជនភៀសខ្លួនដែលគាត់បានជួបនិងសម្ភាសន៍ ។

សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់លើកឡើងអំពីការជម្លៀសអ្នកជម្ងឺចេញមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រុងភ្នំពេញ ហើយអ្នកជម្ងឺមួយចំនួននៅព្យួរសេរ៉ូមជាប់នឹងដៃនៅឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នោះក៏លើកឡើងផងដែរថា ខ្មែរក្រហមមិនបានផ្តល់អាហារ ថ្នាំ និង ទីលំនៅដល់ប្រជាជនជម្លៀសនោះ ។ សាក្សីបញ្ជាក់ជូនអង្គជំនុំជម្រះជាថ្មីម្តងទៀតថាគាត់បានដឹងនិងស្តាប់ការលើកឡើងដូចគ្នានេះដែរ ។ សាក្សីបន្ថែមថាជនភៀសខ្លួនមួយចំនួនបានលើកឡើងប្រាប់គាត់ពីការទទួលបានអាហារ គ្រប់គ្រាន់និងមធ្យោបាយធ្វើដំណើរ ។ សាក្សីអង្គុយផ្អែកនឹងកៅអី ហើយអង្គុយបង្អិលចុះឡើងតិចៗ ហើយបន្តពិភាក្សាអំពីលក្ខខណ្ឌផ្សេងគ្នានៅតាមតំបន់ផ្សេងៗទូទាំងប្រទេស ។

បន្ទាប់ពីសាក្សីបញ្ចប់ការពន្យល់របស់ខ្លួន សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីអានការដកស្រង់មួយទៀតនៅចំពោះមុខអង្គជំនុំជម្រះ ។ ការដកស្រង់នេះនិយាយថា«ពេលខ្ញុំទៅដើរ ខ្ញុំបានឃើញសាកសពមនុស្សពីរ-បីនាក់ត្រូវបានគេបាញ់សម្លាប់ ។ ខ្មែរក្រហមភ្ជង់កាំភ្លើងដាក់យើងហើយបញ្ជាមិនឲ្យយើងទៅណាទេ ។ ខ្ញុំឃើញខ្មែរក្រហមបាញ់សម្លាប់មនុស្សពីរ-បីនាក់ផ្ទាល់នឹងភ្នែក ។ ជាក់ស្តែង អ្នកទាំងបីនាក់នោះគឺជាម្ចាស់ផ្ទះ ហើយត្រូវខ្មែរក្រហមបាញ់សម្លាប់ដោយសារតែគាត់មិនព្រមចាកចេញពីផ្ទះតាមការបញ្ជារបស់ខ្មែរក្រហម» ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះលើកឡើងបន្ថែមថា ខ្មែរក្រហម បានប្រកាសឲ្យប្រជាជនចាក់ចេញពីផ្ទះតែបីថ្ងៃ ហើយបន្ទាប់ពីបីថ្ងៃហើយគេអាចត្រលប់មកផ្ទះវិញ ។

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចោទសួរសាក្សីថា តើគាត់មានបានដឹងព័ត៌មានដូចគ្នានឹងការលើកឡើងរបស់ដើម្បបណ្តឹងរដ្ឋប្បវេណីខាងលើនេះទេ ។ សាក្សីឆ្លើយថា គាត់បានដឹងថាប្រជាជនត្រូវ

បានបាញ់សម្លាប់នៅបាត់ដំបង និងការបោកបញ្ឆោតប្រជាជនឲ្យចាកចេញពីផ្ទះ ក៏ប៉ុន្តែ គាត់មិនបានដឹងពីការកំណត់ឲ្យចាក់ចេញពីផ្ទះត្រឹមតែបីថ្ងៃនោះទេ ។

សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ស៊ីម៉ុណូហ្វត លើកឡើងនិងអានសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀត ឈ្មោះ ពុធ ឌីណា ដែលបានរៀបរាប់ថា ខ្មែរក្រហមបានប្រកាសតាមម៉េក្រូ និងប្រាប់គាត់ឲ្យចុះឈ្មោះជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជា ។ ប្ដីរបស់គាត់ចង់ទៅចុះឈ្មោះ ប៉ុន្តែគាត់ឃាត់ប្ដីគាត់កុំឲ្យទៅចុះឈ្មោះ ។ ពេលដែលគាត់ទៅចុះឈ្មោះភ្លាម ខ្មែរក្រហមចាត់គាត់ជា«ប្រជាជន១៧ មេសា» ហើយជាលទ្ធផល គាត់មិនដែលរស់នៅបានស្រណុកស្រួលឡើយ ដោយហេតុថាគាត់ត្រូវធ្វើការយូរជាងអ្នកដទៃ ។

សាក្សីបញ្ជាក់ការ ហេតុការណ៍ដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះលើកឡើង គឺកើតមានជាទូទៅក្នុងសម័យនោះ ។

មកដល់ចំនុចនេះ មេធាវីការពារក្ដី កុបប៉េ បានធ្វើការជំទាស់នឹងការចោទសួររបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីទៅលើសាក្សី ។ មេធាវីការពារក្ដី កុបប៉េ លើកឡើងថាការចោទសួរទាំងនេះមិនមានពាក់ព័ន្ធជាមួយនឹងការស្រាវជ្រាវរបស់សាក្សីនោះទេ ហើយមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមកចោទសួរសាក្សីជាសំនួរនាំមុខ ។ មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបវិញថា គាត់បានប្រើប្រាស់វិធីសាស្ត្រនេះអស់រយៈពេល ១៨ខែមកហើយ ។ លោក ប្រធានអង្គជំនុំជម្រះបានច្រានចោលការជំទាសរបស់មេធាវីការពារក្ដី ហើយអនុញ្ញាតឲ្យមេធាវីនាំមុខ ដើមបណ្ដឹងរដ្ឋប្បវេណីបន្តចោទសួរសាក្សី ។

សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ស៊ីម៉ុណូហ្វត ចោទសួរសាក្សីថាតើគាត់បានដឹងថាខ្មែរក្រហមបានធ្វើដាក់«ប្រជាជនថ្មី»ដោយរបៀបណាខ្លះ ។ សាក្សីឆ្លើយថាគាត់បានជួបនឹងមនុស្សជាច្រើនដែលខ្មែរក្រហមចាត់ទុកជាប្រជាជនថ្មី ហើយទង្វើរដែលខ្មែរក្រហមធ្វើដាក់ក្រុមរបស់គាត់មានលក្ខណៈភ្លែកៗពីគ្នា ។

នៅពេលដែលសួរដេញដោលពីការប្រព្រឹត្តខុសគ្នាដែលខ្មែរក្រហមបានធ្វើដាក់ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី អានសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ អាស ហុងឌ្វី ដូចខាងក្រោមនេះ ៖

> ឯកសារដាក់ស្ដែងពីទង្វើខុសគ្នាទៅលើប្រជាជនថ្មី និងប្រជាជនមូលដ្ឋានគឺជាបែងចែកអង្ករ ។ យើងជាប្រជាជនថ្មីទទួលបានរបបតែមួយវែកទេ តែប្រជាជនមូលដ្ឋានទទួលបានរបបពីរវែក ។ ស្ត្រីដែលប្រជាជនមូលដ្ឋានមិនចាំទៅធ្វើការនោះទេ នៅពេលដែលឆ្លងទន្លេ ។ ប្រជាជនមូលដ្ឋានហូបសាច់និងត្រី ហើយប្រជាជនថ្មីបានត្រឹមតែហូបបាយជាមួយនឹងអំបិលតែប៉ុណ្ណោះ ។ ក្រៅពីបានរបបអាហារមួយវែកនេះ យើងហូបកន្ទែបប្រផិត និង ខ្ទារដំរី ។ យើងដណ្ដើមអាហារគ្នាហូបបីដូចជាសត្វធាតុអ៊ីចឹង ។

នៅពេលដែលសួរថាតើលោកបានធ្លាប់ដឹងពីសក្ខីកម្មដូចគ្នានឹងការលើកឡើងខាងលើនេះឬទេ សាក្សីបានឆ្លើយភ្លាមៗវិញថា គាត់បានដឹងនិងពិនិត្យសក្ខីកម្មបែបនេះ បើគិតជាចំនួនវិញ “គឺនៅចន្លោះពីមួយចំនួននិងជាច្រើន” ។

បន្ទាប់មកទៀត សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ស៊ីម៉ុណូហុត លើកឡើងពីប្រធានបទចោរលួចរបស់តិចតួចដែលសហព្រះរាជអាជ្ញាលើកមកពិភាក្សាកាលពីថ្ងៃមុន ។ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី អានការដកស្រង់មួយនៃសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ ដែលអះអាងថា “ចំណែកឯប្រជាជនខ្មែរដ៏ទៃទៀត ខ្ញុំឃើញនាំយកក្រុមនោះយកទៅបាត់ៗតែម្ដង ដោយគ្មានអនុគ្រោះសោះឡើយ បើទោះជាគេគ្រាន់តែលួចស្លឹកត្នោត និងស្រូវបន្តិចបន្តួចប៉ុណ្ណោះ ។ ខ្មែរក្រហម សម្លាប់ ធ្វើទារុណកម្មនិងវៃចោរប្រភេទនេះរហូតដល់ស្លាប់” ។ កូនពីរនាក់របស់ដើមបណ្ដឹងរូបនេះត្រូវខ្មែរក្រហមសម្លាប់ដោយសារតែគេលួចរបស់បន្តិចបន្តួចប៉ុណ្ណោះ ។ តាមរយៈសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ កូនរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ ដោយសារតែគេរើសយកមែកឈើ ដែលគេកាប់រួចហើយនៅខណៈ ពេលអ្នកទាំងពីរត្រូវបានចាត់តាំងឲ្យទៅប្រមូលនិងកាប់អុស ។

ដោយសារតែប្រជាជនមានទោសកំហុសបន្តិចបន្តួចនេះ ទើបខ្មែរបន្តជម្លៀសគេដោយបង្ខំទៅកន្លែងថ្មីផ្សេងទៀត ។ សាក្សីលើកឡើងថាខ្មែរក្រហមធ្វើការជម្លៀសប្រជាជនតាមកាណូត ឡាន និង រថភ្លើង ។

សាក្សីបន្ថែមទៀតថា ជាធម្មតាកងសន្តិសុខតែងតែដើរយាមនិងធ្វើដំណើរជាមួយនឹងអ្នកជម្លៀស ហើយពេលដែលទៅដល់កន្លែងថ្មី អ្នកជម្លៀសអស់កម្លាំងជាងមុន ធ្លាក់ខ្លួនឈឺ និងហេវហត់ជាមុន ។

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អានការដកស្រង់ពីសក្ខីកម្មដើមបណ្តឹង ដែលលើកឡើងថា កាណូត ឡាន និងរថភ្លើងដែលដឹកអ្នកជម្លៀសមានលក្ខណៈចង្អៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក៏បានលើកឡើងពីការលំបាកផ្សេងៗទៀតដែលអ្នកជម្លៀសឆ្លងកាត់ ហើយសាក្សីបញ្ជាក់ថាគាត់បានដឹងពីការលើកឡើងដូចគ្នានេះជាច្រើនដងមកហើយ ។

ទាក់ទឹងបញ្ហាភាសា សាក្សីបានលើកឡើងរួចហើយថាគាត់អាចប្រើភាសាខ្មែរយ៉ាងស្ទាត់ជំនាញ ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចោទសួរសាក្សីថាតើគាត់បានដឹងពីពាក្យវាយសព្ទមួយចំនួនដែលមេដឹកនាំខ្មែរក្រហមបានប្រើនៅពេលនោះឬទេ ។ សាក្សីឆ្លើយតបថា ខ្មែរក្រហមបានប្រើប្រាស់គ្រាមភាសាខាងផ្នែកនយោបាយ ឧទាហរណ៍ដូចជាការប្រើពាក្យ “ផលិតផល” ។ សាក្សីនៅចាំថាកម្មាភិបាលខ្មែរក្រហម និងប្រជាជនទូទៅប្រើពាក្យនេះនៅសម័យខ្មែរក្រហម ។ ពេលដែល សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចោទសួរសាក្សីថាតើពាក្យមានប្រើនៅក្នុងឯកសារខ្មែរក្រហមដែរឬទេ មេធាវីការពារក្តី គុបប៉េ បានធ្វើការជំទាស់ដោយជោគជ័យ ដោយអះអាងថាសាក្សីរូបនេះមិនមានជាសាក្សីជំនាញនោះទេ ពីព្រោះជាក់ស្តែងគាត់កំពុងតែធ្វើសក្ខីកម្មជាសាក្សីធម្មតាតែប៉ុណ្ណោះ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចេត វ៉ាន់លី ចោទសួរសាក្សីពីការលុបបំបាត់ទីផ្សាររបស់ខ្មែរក្រហម ។ សាក្សីបកស្រាយថាខ្មែរក្រហមបានលុបបំបាត់ទីផ្សារតាំងពីឆ្នាំ១៩៧៣ ហើយខ្មែរក្រហមបានធ្វើការហាមប្រាមការប្រើប្រាស់ក្រដាសប្រាក់នៅក្នុងតំបន់រំដោះទៀតផង ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចេត វ៉ាន់លី បានប្តូរប្រធានបទទៅពិភាក្សាអំពីជនជាតិភាគតិចខ្មែរ-ឥស្លាម ។ សាក្សីបានដឹងពីការប្រព្រឹត្តរបស់ខ្មែរក្រហមទៅលើជនជាតិភាគតិចខ្មែរ-ឥស្លាម ដែលចេះតែលំបាកទៅៗចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ។ សាក្សីបានធ្វើការបកស្រាយយ៉ាងលម្អិតអំពីផលលំបាកដែលបងប្អូនជនជាតិភាគតិចឥស្លាមជួបប្រទះនៅសម័យខ្មែរក្រហមដែលមានដូចជា ការរឹតបន្តឹងការប្រតិបត្តិសាសនាឥស្លាម និងការជម្លៀសនិងបំបែកជនជាតិភាគតិចខ្មែរ-ឥស្លាមឲ្យនៅ តំបន់

ផ្សេងៗពីគ្នា ។ សាក្សីលើកឡើងផងដែរ កម្មាភិបាលជនជាតិភាគតិចខ្មែរឥស្លាមមួយចំនួនបានអនុវត្តនយោបាយប្រឆាំងនឹងជនជាតិខ្មែរ-ឥស្លាមរបស់ខ្មែរក្រហម ។

បន្ទាប់ពីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ចេត វ៉ាន់លី បញ្ចប់ការសាក់សួរសាក្សីអំពីផលប៉ះពាល់នៃគោលនយោបាយខ្មែរក្រហមទៅលើជនជាតិភាគតិចឥស្លាម លោកមេធាវី គង់ សំអុន បានធ្វើការជំទាស់នឹងសំនួរនេះប្រកបដោយជោគជ័យ ដោយអះអាងសំនួរនេះជាសំនួរសម្រាប់សួរទៅកាន់សាក្សីជំនាញនោះទេ ។

នៅពេលដែលត្រូវបានចោទសួរពីទំនាក់ទំនងមជ្ឈិមបក្សនិង ថ្នាក់ស្រុក សាក្សី លើកឡើងពី សារទូលេខ ទំនាក់ទំនងជាលាយលាក់អក្សរ របាយការណ៍ និង កិច្ចប្រជុំដែលជាមធ្យោបាយមួយដែលខ្មែរក្រហមបានប្រើប្រាស់ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់ការដេញដោលសួររបស់ខ្លួនទៅកាន់សាក្សី ។

## កិច្ចពិភាក្សាអំពីសារណារបស់មេធាវីការពារក្ដី នួន ជា

ចៅក្រម និល ណុន ប្រធានអង្គជំនុំ ជម្រះសាលាដំបូង មិនបានប្រគល់វេទិការទៅឲ្យមេធាវីការពារក្ដីសួរដេញដោលសាក្សី ប៉ុន្តែអនុញ្ញាតឲ្យភាគីទាំងអស់ដែលពាក់ពន្ធ័ដាក់សេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងសារណារបស់មេធាវីការពារក្ដី នួន ជា ដែលទាមទារឲ្យដាក់បញ្ចូលភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ហើយអង្គជនុំជម្រះស្ដាប់សក្ខីកម្មរបស់សាក្សីម្នាក់ ដែលមានឈ្មោះសម្ងាត់ TCW382 ។

មេធាវី ហ្គីសសេ ចាប់ផ្ដើមលើកយកបញ្ហានេះមកធ្វើការពិភាក្សាមុនគេ. មេធាវី ហ្គីសសេ និយាយគាំទ្រសារណាររបស់មេធាវីការពារក្ដី នួន ជា ចាប់ពីកាចាប់ផ្ដើមសវនាការដេញដោលពីភស្តុតាង ពីព្រោះមេធាវីការពារក្ដីរបស់ ខៀវ សំផន អះអាងថាអង្គជំនុំជម្រះមិនអាចមើលខ្សែភាពយន្តនេះរហូតដល់ចប់នោះទេ ហើយចំនុចដែលកាត់តចេញពីខ្សែភាពយន្តនេះក៏មិនគួរយកមកបញ្ចាំងនៅចំពោះមុខអង្គជំនុំជម្រះនោះដែរ ។ មេធាវី ហ្គីសសេ អះអាងថាឯកសារដោះបន្ទុករបស់មេធាវីការពារក្ដី នួន ជា ក៏ជាឯកសារដោះបន្ទុកសម្រាប់មេធាវីការពារក្ដី ខៀវ សំផន ផងដែរ ។ ដូច្នេះ មេធាវី ហ្គីសសេ បានធ្វើសេចក្ដីសន្និដ្ឋានថា ការដាក់បញ្ចូលភស្តុតាងរបស់សាក្សី TCW382 ដែលជា

ផលិតករម្នាក់របស់ខ្សែភាពយន្ត សត្រូវប្រជាជន ពិតជានឹងពាក់ព័ន្ធនិងចំបាច់សម្រាប់ធានាឲ្យមានការកាត់ទោសប្រកបដោយយុត្តិធម៌សម្រាប់ចុងចោទ ។

សហព្រះរាជអជ្ញា ថារីក អាប់ឌុលហាក់ ថ្លែងទៅកាន់អង្គជំនុំជម្រះដោយលើកឡើងបីចំណុចដែលបានមាននៅក្នុងសារណារបស់មេធាវីការពារក្តី នួន ជា ទីមួយ សារអេឡិចត្រូនិចរបស់សាក្សី TCW382 ដែលត្រូវបានស្នើសុំឲ្យដាក់ជាភស្តុតាងបន្ថែមនៅក្នុងសំណុំរឿង ទីពីរ ការស៊ើបអង្កេតលើឯកសារដោះបន្ទុកដែលមាននៅក្នុងដៃរបស់សាក្សី TCW382 និង ទីបី ការកោះហៅសាក្សី TCW382 ឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។

ការិយាល័យសហព្រះរាជអជ្ញាជំទាស់នឹងការបញ្ចូលសារអេឡិចត្រូនិចរបស់សាក្សី TCW382 ទៅក្នុងសំណុំរឿង និងការកោះសាក្សីឲ្យមកផ្តល់សាក្សីកម្ម ។ សហព្រះរាជអជ្ញា អាប់ឌុលហាក់ បកស្រាយថាការិយាល័យសហព្រះរាជអជ្ញាយល់ស្របដោយផ្អែកទៅនឹងសំណើរទីបីរបស់មេធាវីការពារក្តី នួន ជា ។

សហព្រះរាជអជ្ញា អាប់ឌុលហាក់ ចាប់ផ្តើមដោលលើកឡើងថាសហព្រះរាជអជ្ញាមានការភ្ញាក់ផ្អើលពេលឃើញការចែករំលែកព័ត៌មានពីមនុស្សម្នាក់ដែលបានបដិសេធធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការកាលពីលើកមុន ។ លើសពីនេះទៅទៀត សហព្រះរាជអជ្ញា អាប់ឌុលហាក់បន្ថែមថាសាក្សី TCW382 គួរតែទាក់ទងមកអង្គជំនុំជម្រះជាជាង ទាក់ទងជាមួយនឹងមេធាវីការពារក្តី នួន ជា ដោយសារការធ្វើ បែបនេះសមហេតុផលជាង ។ នៅក្នុងសារណារបស់ខ្លួន សហព្រះរាជអជ្ញាលើកឡើងថា TCW382មានព័ត៌មានបន្តិចបន្តួចដើម្បីផ្តល់ឲ្យតុលាការ ហើយសហព្រះរាជអជ្ញាបានពិនិត្យមើលពីតួនាទីរបស់សាក្សី TCW382 ក្នុងការផលិតខ្សែភាពយន្តនេះ ។ សហព្រះរាជអជ្ញាលើកហេតុផលថាខ្សែភាពយន្តនេះ កំពុងតែស្ថិតនៅក្នុងដំណាក់កាលកាត់ត ។ សហព្រះរាជអជ្ញា អាប់ឌុលហាក់ បន្ថែមទៀត ទោះបីជា TCW382 ជាអ្នកផលិតខ្សែភាពយន្តដ៏ជំនាញម្នាក់ ប៉ុន្តែគាត់មានជាអ្នកជំនាញពីប្រវត្តសាស្ត្របក្ស កម្មុយនីសកម្ពុជានោះទេ ។

សហព្រះរាជអជ្ញាលើកឡើងថា ការិយាល័យរបស់ខ្លួនបានបញ្ជូនឯកសារបីច្បាប់ជូនភាគីដែលពាក់ព័ន្ធកាលពីចុងសប្តាហ៍ ។ នៅក្នុងឯកសារទីមួយ នៅពេលដែលសួរថាតើសាក្សី TCQ720 ទទួលបានជោគជ័យអ្វីខ្លះពីការផលិតខ្សែភាពយន្ត សត្រូវប្រជាជន សាក្សី TCW382 ឆ្លើយថា «សាក្សី TCQ720 បាន

យល់ដឹងច្រើនថែមទៀតអំពីរបបខ្មែរក្រហម ជាងពេលមុន» ។ សហព្រះរាជអជ្ញា អាប់ឌុលហាក់ យល់ការឆ្លើយតបនេះហាក់ដូចជាមិនអាចទទួលយកបានសម្រាប់ព្រះរាជអជ្ញា ពីព្រោះថាចម្លើយនេះបានបង្ហាញថា TCQ720 មិនបានពិនិត្យមើលឯកសាយ៉ាងច្រើនណាទាក់ទងនឹងរបបខ្មែរក្រហម និងធ្វើការស្រាវជ្រាវយ៉ាងលម្អិត ដូចដែលលោក ហេដ្ឋឌ័រ ហ៊ូលីព ស៊ត ដេវីត ឆេនល័រ និង បេន គៀនន់ បានធ្វើនោះទេ ។

ជាងនេះទៅទៀត សហព្រះរាជអជ្ញា អាប់ឌុលហាក់ បន្ថែមទៀតថាមានភាពមិនច្បាស់នៅក្នុងសារអេឡិចត្រូនិចរបស់សាក្សី TCW382 ដែលធ្វើឲ្យសហព្រះរាជអជ្ញាបារម្ភថាតើព័ត៌មាននេះអាចទុកជាការបានដែរឬអត់ ។ សហព្រះរាជអជ្ញាលើកឧទាហរណ៍ ដោយអានកថាខណ្ឌទីពីរ ដែលសាក្សី TCW382 លើកឡើងថា នួន ជា «មិនយល់ស្របនឹងការសម្រេចឲ្យសម្លាប់អ្នករដ្ឋការជាន់ខ្ពស់របស់របបលន់ នល់ ។ ហើយតាមដែល នួន ជា ចាំបាន មានរដ្ឋមន្ត្រីរដ្ឋការលន់ នល់ ប្រហែលជាប្រាំមួយនាក់ និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត ត្រូវបាននាំមកកាត់ទោសដោយតុលាការយោធា និងទទួលរងទោសប្រហារជីវិត ។ ហើយ នួន ជា មិនមានមានពាក់ព័ន្ធនៅក្នុងហេតុការណ៍នេះទេ» ។

សហព្រះរាជអជ្ញាឆ្លើបនឹងការអះអាងនេះវិញថា នៅត្រង់នាទីទី២២ក្នុងខ្សែភាពយន្តនេះ នួន ជា បាននិយាយថាមន្ត្រីជាន់ខ្ពស់ «ត្រូវយកទៅសម្លាប់ ហើយពួកគេសមនឹងទទួលទោសប្រហារជីវិត» ។ សហព្រះរាជអជ្ញា អាប់ឌុលហាក់ អះអាងថាបើយើងធ្វើប្រៀបធៀបការលើកឡើងទាំងពីរខាងលើនេះ សាក្សី TCW382 កំពុងតែផ្តល់ «ភស្តុតាងដក់បន្ទុកដល់ នួន ជា ជាង នួន ជា ខ្លួនឯងទៅទៀត» ហើយ សាក្សីខ្លួនឯងផ្ទាល់ធ្វើការបកស្រាយខុសនឹងអ្វីដែលមាននៅក្នុងខ្សែភាពយន្តរបស់គាត់ ។

ព្រះរាជារអជ្ញាបន្ថែមទៀតថា សាក្សីមិនមានវត្តមានទេ នៅពេលដែល នួន ជា ផ្តល់បទសម្ភាសន៍ ហេតុដូច្នេះហើយបានជាសាក្សីរូបនេះមិនបានផ្តល់ព័ត៌មានចាំបាច់ច្រើនដល់តុលាការនោះទេ ។ សហព្រះរាជអជ្ញា អាប់ឌុលហាក លើកយកបទសម្ភាសន៍ជាមួយនឹងវិទ្យុ Prague ដែលសាក្សី TCW382 បានបញ្ជាក់យ៉ាងច្បាស់ថាមានតែសាក្សី TCQ720 ទេ ដែលបានទទួលបានការទុកចិត្តពី នួន ជា ហើយបានធ្វើបទសម្ភាសន៍នេះ ។

សហព្រះរាជអជ្ញា អាប់ឌុលហាក លើកឡើងឯកសារទីពីរ ដែលជាបទសម្ភាសន៍របស់សាក្សី TCW382 ជាមួយនឹងការសែត The Independent ។ សហព្រះរាជអជ្ញាបញ្ជាក់ថានៅក្នុងបទសម្ភាសន៍នេះ សាក្សីបាននិយាយថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានលទ្ធភាពស្វែងរកការពិត និងការផ្សះផ្សាជាតិជូនប្រជាជននោះទេ ។ នៅក្នុងបទសម្ភាសន៍ដដែរនេះ សាក្សី TCW382 បញ្ជាក់ថា សាក្សី TCQ720 អាចធ្វើបទសម្ភាសន៍ជាមួយនឹង នួន ជា បានដោយព្រមព្រៀងថានឹងមិនយកបទសម្ភាសន៍នេះទៅប្រើប្រាស់ដើម្បីដាក់បន្ទុកលើ នួន ជា នោះទេ ហើយប្រសិនបើ សាក្សី TCQ720 ប្រគល់ បទសម្ភាសន៍ទាំងអស់នោះទៅតុលាការ គាត់នឹងក្បត់ នួន ជា ជាមិនខាន ។

សហព្រះរាជអជ្ញា អាប់ឌុលហាក សន្និដ្ឋានថាសារអេឡិចត្រូនិចរបស់សាក្សីមិនអាចយកមកប្រើការ បាននោះទេ ។ សហព្រះរាជអជ្ញាបន្ថែមថា នួន ជា អាចនិយាយការពារខ្លួនគាត់ ហើយបញ្ជាក់ថា វាជារឿងមិនត្រឹមទាល់តែសោះបើសិនជាតុលាការ យកសារអេឡិចត្រូនិចនេះមកធ្វើជាភស្តុតាង ពីព្រោះការលើកឡើងរបស់ នួន ជា នៅក្នុងខ្សែរភាពយន្ត មិនបានដូចគ្នា និងគាំទ្រការលើកឡើងរបស់សាក្សីនៅក្នុងសារអេឡិចត្រូនិចរបស់ខ្លួនសោះ ។

សហព្រះរាជអជ្ញាបញ្ជាក់ម្តងទៀត ការិយាល័យសហព្រះរាជអជ្ញាធ្វើការជំទាស់នឹងការកោះហៅសាក្សី TCW382 ឲ្យធ្វើជាសក្សីឡើងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយសារតែសាក្សីមិនបានដឹងនូវអង្គហេតុដែលពាក់ពន្ធ័ ។

តែទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអជ្ញា អាប់ឌុលហាក លើកឡើងថាការិយាល័យសហព្រះរាជអជ្ញាគាំទ្រនឹងផ្នែកមួយចំនួននៃចំណុចស្នើរសុំចុងក្រោយរបស់មេធាវីការពារក្តី នួន ជា ឲ្យមានការស៊ើបអង្កេតលើបញ្ហានេះ ។ សហព្រះរាជអជ្ញាបន្ថែមទៀតថាការិយាល័យសហព្រះរាជអជ្ញាគាំទ្រការស្នើរសុំឯកសារដើមទាំងឡាយដែលបានប្រើក្នុងការផលិតខ្សែភាពយន្តនេះ និងសៀវភៅដែលសរ សេរដោយ នួន ជា ផ្ទាល់ ។ ប៉ុន្តែសហព្រះរាជអជ្ញា ជឿជាក់ថាសាក្សី TCW382 នឹងមិនធ្វើការឆ្លើយតបនិងសហការណ៍ជាមួយតុលាការទាក់ទងនឹងសំណើរនេះទេ ដោយហេតុថាសាក្សីរូបនេះមិនបានធ្វើកិច្ចសហការណ៍ជាមួយនឹងតុលាការកាលពីពេលមុននោះទេ ។

លោកសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ ជម្រាបជូនអង្គជំនុំជម្រះថា សហការីរបស់ខ្លួនគឺមេធាវី ស៊ីម៉ុណូហ្វុត បានបង្ហាញពីជំហររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីកាលពីសវនាការលើកមុនរួចហើយ ។ លោកសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បញ្ជាក់បន្ថែមថា សាក្សី TCW382 មិនមានជាអ្នកជំនាញនោះទេ ដូច្នេះតុលាការមិនគួរកោះហៅសាក្សីរូបនេះឲ្យមកផ្តល់សក្ខីកម្មនោះទេ ។

បន្ទាប់មក សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ុណូហ្វុត យកគោលការណ៍ «ច្បាប់» មកធ្វើការបកស្រាយ ហើយអះអាងថាបើសិនតុលាការមិនអនុញ្ញាតឲ្យមេធាវីការពារក្តី កុបប៉េ យកសារអេឡិចត្រូនិចរបស់សាក្សី TCW382 ធ្វើជាភស្តុតាង ដូច្នេះតុលាការគួរប្រានចោលនូវសំណើររបស់មេធាវីការពារក្តីរបស់ នួន ជា ផងដែរ ។ មេធាវី ស៊ីម៉ុណូហ្វុត អះអាងថាសារអេឡិចត្រូនិចមិនអាចយកមកប្រើប្រាស់បាននោះទេ ។ លើសពីនេះទៀត មេធាវី ស៊ីម៉ុណូហ្វុត ចោទជាសំនួរថាបើសិនជាអះអាងថាគាត់មិនបាននិយាយពីការសម្លាប់មន្ត្រីរដ្ឋការជាន់ខ្ពស់លន់ នល់ នោះ តែជាក់ស្តែងគាត់បាននិយាយក្នុងខ្សែភាពយន្តនេះ ហេតុអ្វីបានជាគាត់មិនធ្វើការជំទាស់កាលពីពីរឆ្នាំកន្លះមុន?

បន្ទាប់ពីមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួន មេធាវីការពារក្តី កុបប៉េ បានក្រោកឡើងហើយឆ្លើយតបថាគាត់បានស្តាប់ «ការលើកឡើងការលើកឡើងដោយមិនហេតុផលជាច្រើនដែលជម្រុញឲ្យគាត់ឆ្លើយតប» ហើយសូមទោសផងដែរដល់ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដោយសារតែ «ខ្ញុំមិនអាចឃាត់ខ្លួនឯងបាន!» ។ លោកប្រធានអង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីការពារក្តី កុបប៉េ ការឆ្លើយតបយ៉ាងសង្ខេប ដោយហេតុថាការក្រោកឈរតវ៉ាភ្លាមៗរបស់មេធាវីការពារក្តីនៅពេលនេះជាអាកប្បកិរិយាមិនសមរម្យមួយក៏ដោយ ។

ទីមួយ មេធាវីការពារក្តី កុបប៉េ អះអាងថា សាក្សី TCW382 មិនបានចាត់ទុកខ្លួនគាត់ថាជាអ្នកជំនាញនោះទេ តែគ្រាន់តែមនុស្សម្នាក់ ដែលចង់ឡើងមកបកស្រាយនូវអ្វីដែលខ្លួនបានដឹង បន្ទាប់ពីបានអានសក្ខីកម្មដែលបានលើកយកមកពិភាក្សាក្នុងអំឡុងពេលសវនាការ ។

ទីពីរ មេធាវីការពារក្តី កុបប៉េ បញ្ជាក់ថាខ្សែភាពយន្តមានសារៈសំខាន់ណាស់ ហើយតុលាការបានប្រើប្រាស់ខ្សែភាពយន្តនេះជាច្រើនដងមកហើយ ។ គាត់បន្ថែមថា ហេតុដូច្នេះហើយ ផលិតករភាពយន្តនេះ

គួរត្រូវបានអនុញ្ញាតឲ្យឡើងមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយជាពិសេស សាក្សីរូបនេះអាចបង្ហាញពីភស្តុតាងដែលបញ្ជាក់ថា នួន ជា មិនមានការពាក់ព័ន្ធនឹងព្រឹត្តការណ៍ដែលកើតនៅ ទួលពោធិ៍ជ្រៃនោះទេ ។

មេធាវីការពារក្ដី កុបប៉េ បន្តថាបើសិនជា នួន ជា មិនជំទាស់នឹងការចាប់បញ្ចាំងខ្សែភាពយន្តនេះទេ ដូច្នេះការដាក់បញ្ចូលខ្សែភាពយន្តនេះ ជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះក៏មិនមែនជាបញ្ហាអ្វីនោះដែរ ពីព្រោះថាការធ្វើបែបនេះនឹងមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងរវាង នួន ជា និងផលិតករខ្សែភាពយន្តនេះ ។ មេធាវីការពារក្ដី កុបប៉េ និយាយថា បើទោះបីជាសវនាការថ្ងៃនេះជិតនឹងបញ្ចប់មែនក៏ដោយ ប៉ុន្តែមិនមានមានន័យភាគីទាំងអស់មិនចាំធ្វើការដេញដោលក្នុងបញ្ហាភស្តុតាងនេះដែរ ។ មេធាវីការពារក្ដី កុបប៉េ បន្ថែមថា «យើងកំពុងតែស្វែងរកការពិត ។ ហើយពេលនេះ យើងមានសក្សីម្នាក់ដែលបានចំណាយពេលវេលារាប់ម៉ោងថតខ្សែភាពយន្តដែលតុលាការកំពុងតែធ្វើការពិភាក្សា ។ មេធាវី កុបប៉េ បញ្ជាក់ទៀតថាខ្សែភាពយន្តនេះមានសារៈសំខាន់ណាស់ ហើយតុលាការបានប្រើខ្សែភាពយន្តនេះជាច្រើនដងមកហើយ» ។

ចៅក្រម ខាតវ៉្រាយត៍ ចោទសួរមេធាវីការពារក្ដីពីរបីសំនួរ ។ ទីមួយ ចៅក្រម ខាតវ៉្រាយត៍ តើមេធាវីការពារក្ដីដឹងថាសាក្សី TCW382 នឹងសហការណ៍ជាមួយតុលាការដោយរបៀបណា ។ មេធាវីកាពារក្ដី កុបប៉េ ជឿជាក់ថាសារអេឡិចត្រូនិចរបស់សាក្សីបង្កប់ន័យថាគាត់នឹងសហការណ៍ជាមួយនឹងតុលាការ ។ ទីពីរ ចៅក្រមខាតវ៉្រាយត៍ ចង់ដឹងថាតើក្រុមសីលធម៌អ្នកការសែតនឹងជម្រុញឲ្យគាត់មិនឲ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដែលឬទេ ។ មេធាវីការពារក្ដី កុបប៉េ ឆ្លើយតបថាចំនុចនេះនឹងមែនជាបញ្ហាចោទនោះទេនៅពេលដែលមានការអនុញ្ញាតពី នួន ជា ។ ប៉ុន្តែ ពេលដែលចៅក្រម ខាតវ៉្រាយត៍ លើកឡើងថាសាក្សីត្រូវតែការពារអ្នកផ្ដល់ព័ត៌មានផ្សេងទៀត មេធាវីការពារក្ដី កុបប៉េ មិនបានឆ្លើយនឹងសំនួរនេះឲ្យបានច្បាស់លាស់នោះទេ ដោយលើកឡើងថានេះគឺជាបញ្ហាដែលសាក្សី TCW382 នឹងដោះស្រាយដោយខ្លួនលោកផ្ទាល់ ។

សវនាការនៅថ្ងៃនេះបានបញ្ចប់ ហើយអង្គជំនុជម្រះនឹងបន្តស្ដាប់សក្ខីកម្មរបស់លោក ហេដឺរ នៅថ្ងៃអង្គារ៍ ទី១៦ ឆ្នាំ២០១៣ ។ ប្រធានអង្គជំនុំជម្រះសាលដំបូងប្រកាសថាអង្គជំនុំជម្រះនឹងចេញសេចក្ដីលើសារណារបស់មេធាវីការពារក្ដី នួន ជា នៅពេលខាងមុខ ។ **–ចប់–**